# ព្រះរាជក្រម

នស/រកម/០១០២/០០៦

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល-កម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមាន សេចក្តីទាំងស្រុង ដូចតទៅ :

# ច្បាប់
# ស្តីពី
# ការទូទាត់ថវិកាទូទៅរបស់រដ្ឋ
# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានយល់ព្រមតាមការអនុវត្តន៍នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ។ ការអនុវត្តន៍នេះ លេចចេញជាលទ្ធផល ដូចមានចែងក្នុងតារាងសរុបខាងក្រោមនេះ ÷

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូល ចំណាយនៃការគ្រប់គ្រង ឆ្នាំ ២០០០ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ ២០០០ | ច្បាប់ទូទាត់ថវិកាឆ្នាំ ២០០០ |
|---|---|---|
| សរុបចំណូល [១] | ២.៣៥៥.០០០ | ២.០៥៦.៥៧៦ |
| សរុបចំណាយ | ២.៣៥៥.០០០ | ២.០៩៤.៤៧៤ |
| ចំនួនអតិរេកនៃគណនេយ្យចំណូល/ចំណាយ | - | [illegible]៧.០៩៨ |
| កិច្ចប្រតិបត្តិការនៃច្បាប់ហិរញ្ញវត្ថុដែលបានអនុវត្តដោយរតនាគារជាតិ | | |
| ចំណូលថវិកា | ១.៦៥៥.០០០ | ១.៥៣៥.៧៩៨ |
| • ចំណូលជាប្រចាំ | ១.៤៨៥.០០០ | ១.៣៩៣.៤៩៨ |
| • ចំណូលជាមូលធនក្នុងប្រទេស | ២០.០០០ | ៦៩.៨២២ |
| • ចំណូលជាមូលធនក្រៅប្រទេស | ១៥០.០០០ | ១១៥.៩៧៨ |
| ចំណាយថវិកា | ១.៦៥៥.០០០ | ១.៥៣៤.៧០០ |
| • ចំណាយជាប្រចាំ | ១.៣១៥.០០០ | ១.២១៥.៤៧៧ |
| • ចំណាយជាមូលធន | ៣៤០.០០០ | ៣១៨.៥២៣ |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទាន ក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរតនាគារជាតិ | | |
| • ធនធានជាមូលធន សំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៧០០.០០០ | ៥៦០.៧៧៤ |
| • ចំណាយជាមូលធនដោយធនធាន សំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៧០០.០០០ | ៥៦០.៧៧៤ |

(១) ក្នុងនោះមានវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានលើកឡើងនេះ គ្រាន់តែជាការចង្អុលបង្ហាញប៉ុណ្ណោះ ពីព្រោះកិច្ចប្រតិបត្តិការដែលបានអនុវត្តផ្ទាល់ដោយហិរញ្ញប្បទានក្រៅប្រទេស មិនឆ្លងកាត់រតនាគារជាតិ និង មិនបានចុះកិច្ចបញ្ជីការគណនេយ្យក្នុងលេខនាររតនាគារជាតិទេ កិច្ចប្រតិបត្តិការនេះគឺគ្រាន់តែជាការប៉ាន់ប្រមាណ ដោយមានវិធានទំនងផ្ទាល់ជាមួយអ្នកផ្តល់មូលនិធិ ។

មាត្រា ២.-

ចំណូលថវិកា ដែលបានអនុវត្តដោយរតនាគារជាតិ ត្រូវបានលំអិតតាមមាតិកា នៅក្នុងតារាង "ក" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយថវិកា ដែលបានអនុវត្តដោយរតនាគារជាតិ ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០០ ត្រូវបានលំអិតតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល និង តាមជំពូកនៅក្នុងតារាង "ខ" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង "ខ១" ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្នុងប្រទេស ដែលបានសំរេចក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០០ និងដែលបានបែងចែកតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល ។

ការប៉ាន់ប្រមាណសំរេចបាន ស្តីពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០០ ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកា និង ចំពោះចំណាយត្រូវបានលំអិតតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល ហើយត្រូវបានបញ្ជាក់ជាបន្តបន្ទាប់នៅក្នុងតារាង "ក" និង "ខ" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង "ខ២" ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្រៅរតនាគារជាតិ ដែលបានសំរេចក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០០ នឹងត្រូវបានបែងចែកតាមក្រសួង និង ស្ថាបន័សាធារណៈប្រហាក់ប្រហែលដោយអ្នកផ្តល់បរទេស ។

# ជំពូកទី ២

## បទប្បញ្ញត្តិ

## ស្តីពីកិច្ចប្រតិបត្តិការថវិកា

មាត្រា ៣.-

ការប្រមូលចំណូល ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទាន អាករ ផលិតផល និង ផលទុន ព្រមទាំងការសំរេចបាននូវអំណោយ មូលនិធិឧបត្ថម្ភ និង ធនធានដែលបានមកពីការខ្ចី ដែលមានចែង នៅក្នុងច្បាប់

ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ មានចំនួនទឹកប្រាក់សរុប........................................................................................................................ ១.៦៥៥.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់.............................. ១.៥៣៥.៧៩៨ លានរៀល

ដូច្នេះមានចំណូលខ្វះចំនួន.................................... (-) ១១៩.២០២ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ ÷

ចំណូលចរន្ត - គំរោង.................... ១.៤៨៥.០០០ លានរៀល

- ការសំរេចបាន... ១.៣៩៣.៤៩៨ លានរៀល

- មានចំនួនខ្វះ......... (-)៩១.៥០២ លានរៀល

ចំណូលជាមូលធនក្នុងប្រទេស - គំរោង............................ ២០.០០០ លានរៀល

- ការសំរេចបាន........... ២៩.៣២២ លានរៀល

- មានចំនួនលើស.... (+)៩.៣២២ លានរៀល

ចំណូលជាមូលធនក្រៅប្រទេស - គំរោង........................ ១៥០.០០០ លានរៀល

- ការសំរេចបាន......... ១១២.៩៧៨ លានរៀល

- មានចំនួនខ្វះ...... (-)៣៧.០២២ លានរៀល

មាត្រា ៤.-

ចំណាយថវិកាទូទៅរបស់រដ្ឋ ដែលមានចែងនៅក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ មានចំនួនទឹកប្រាក់សរុប.............. ១.៦៥៥.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់................................. ១.៥២៨.៧០០ លានរៀល

ដូច្នេះមានចំណាយខ្វះឥណទានថវិកាចំនួន............. (-)១២៦.៣០០ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ ÷

ចំណាយចរន្ត - គំរោង.................. ១.៣១៥.០០០ លានរៀល

- ការសំរេចបាន... ១.២១៥.៤៧៧ លានរៀល

- មានចំនួនខ្វះ........ (-)៩៩.៥២៣ លានរៀល

ចំណាយជាមូលធននៃវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ÷

- គំរោង........................ ៣២០.០០០ លានរៀល

- ការសំរេចបាន........ ៣០៣.៤០៩ លានរៀល

- មានចំនួនខ្វះ.......... (-)១៦.៥៩១ លានរៀល

ចំណាយជាមូលធននៃការវិលស់បំណុល ÷

- គំរោង..............................២០.០០០ លានរៀល
- ការសំរេចបាន..................៩.៨១៤ លានរៀល
- មានចំនួនខ្វះ..........(-)១០.១៨៦ លានរៀល

មាត្រា ៥.-

ការអនុវត្តន៍កិច្ចប្រតិបត្តិការចំណូល និង ចំណាយតាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលបានសំរេចដោយរតនាគារជាតិ ដូចមានចែងនៅក្នុងមាត្រា៣ និង មាត្រា៤ នៃច្បាប់នេះ បានបង្ហាញជាលទ្ធផលនូវអតិរេកគណនេយ្យនៃចំណូល និង ចំណាយដូចតទៅ ÷

- ចំណូលថវិកាដែលបានសំរេចដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ មានចំនួន..........................................................................១.៥៣៥.៧៩៨ លានរៀល
- ចំណាយថវិកាដែលបានសំរេចដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ មានចំនួន..........................................................................១.៥២៨.៧០០ លានរៀល
- អតិរេកគណនេយ្យពិតនៃចំណូលនិងចំណាយ.........(+)៧.០៩៨ លានរៀល

អតិរេកគណនេយ្យនេះ គឺជាលទ្ធផលនៃ ÷

- អតិរេកនៃចំណូល និង ចំណាយចរន្ត.............(+)១៧៨.០២១ លានរៀល
- និងឱនភាពនៅក្នុងកិច្ចប្រតិបត្តិការជាមូលធន (-)១៧០.៩២៣ លានរៀល

ដោយអនុលោមទៅតាមបទប្បញ្ញត្តិក្នុងមាត្រា ៥៧ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស.៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ អតិរេកគណនេយ្យនៃចំណូល និង ចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ មានចំនួនទឹកប្រាក់ (+)៧.០៩៨ លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផល ដែលបានបើកនៅក្នុងលេខានៃរតនាគារជាតិ ។

# ជំពូកទី ៣

## បទប្បញ្ញត្តិស្តីពីវិនិយោគសាធារណៈដោយហិរញ្ញប្បទាន ក្រៅប្រទេសផ្ទាល់ដែលបានអនុវត្តក្រៅរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

មាត្រា ៦.-

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរតនាគារជាតិ និង ដែលបានគ្រោងទុកសរុបចំណូលស្មើនឹងសរុបចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ មានចំនួនទឹកប្រាក់................ ៧០០.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់.................................. ៥២០.៧៧៨ លានរៀល

ដូច្នេះមានចំនួនខ្វះ ............................................................. (-)១៧៩.២២២ លានរៀល ។

# ជំពូកទី ៤

## បទប្បញ្ញត្តិស្តីពី តុល្យភាពហិរញ្ញវត្ថុសាធារណៈសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

មាត្រា ៧.-

តុល្យភាពហិរញ្ញវត្ថុសាធារណៈជាស្ថាពរ នៃថវិកាទូទៅរបស់រដ្ឋបានបង្ហាញនូវប្រភេទនៃកិច្ចប្រតិបត្តិការ ដូចតទៅ ÷

- កិច្ចប្រតិបត្តិការថវិកា : តារាង “ក”: ចំណូលថវិកាទូទៅរបស់រដ្ឋ និង តារាង “ខ” : ចំណាយថវិកាទូទៅរបស់រដ្ឋ ។
- កិច្ចប្រតិបត្តិកានៃរតនាគារជាតិ ។
- ទំនាក់ទំនងហិរញ្ញវត្ថុរបស់រដ្ឋជាមួយនឹងធនាគារជាតិនៃកម្ពុជា ។

តុល្យភាពហិរញ្ញវត្ថុដែលសំរេចបានជាស្ថាពរ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ បានឆ្លុះបញ្ចាំងនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ដូចខាងក្រោម ÷

ឯកតា: លានរៀល

| តារាងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស(+).ឱនភាព(-) |
|---|---|---|
| I - ចំណូលក្នុងប្រទេស | ១.៤២២.៨២០ | |
| ១ - ចំណូលជាប្រចាំក្នុងប្រទេស | ១.៣៩៣.៤៩៨ | |
| ២ - ចំណូលជាមូលធនក្នុងប្រទេស (ឯកជនភាវូបនីយកម្ម) | ២៩.៣២២ | |
| II - ចំណាយថវិកា | ២.០៣៩.៦៦៤ | |
| ១ - ចំណាយជាប្រចាំ | ១.២១៥.៤៧៧ | |
| ២ - ចំណាយជាមូលធន [២] | ៨២៤.១៨៧ | |
| ក្នុងនោះ ÷ | | |
| * វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ៣០៣.៤០៩ | |
| - ដោយមូលនិធិថវិកា | ៣០១.៦១៣ | |
| • គំរោងវិនិយោគ (សាងសង់, ទិញសម្ភារៈ) | ២២០.៦១៥ | |
| • បដិភាគរួមចំណែកជាមួយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៨០.៩៩៨ | |
| - ដោយមូលនិធិក្រៅប្រទេសដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | ១.៧៩៦ | |
| * វិនិយោគសាធារណៈដោយហិរញ្ញប្បទានពីក្រៅប្រទេសផ្ទាល់(ជំនួយគំរោងការ) | ៥២០.៧៧៨ | |
| អតិរេកនៃថវិកាជាប្រចាំ (តាមនិយមន័យសន្យាផ្តល់) | | (+)១៧៨.០២០ |
| ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យសន្យាផ្តល់) | | (-)៦១៦.៨៤៥ |
| III - កំណែតំរូវ | | (+)១០.១៩៥ [៣] |
| អតិរេកនៃថវិកាជាប្រចាំ (តាមនិយមន័យបេឡា) | | (+)១៨៨.១៦៥ |
| ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យបេឡា) | | (-)៦០៦.៧០០ |
| IV - ហិរញ្ញប្បទាននៃឱនភាព | | (+) ៦០៦.៧០០ |
| ១ - ហិរញ្ញប្បទានក្រៅប្រទេស | | (+) ៦៣៥.៦៦១ |
| • ជំនួយទ្រទ្រង់ថវិកាមិនមានកំណត់មុខសញ្ញាចំណាយ | | 0 |
| • ជំនួយទ្រទ្រង់ថវិកាដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | | (+) ១១២.៩៧៨ |
| • ជំនួយគំរោងការ | | ៥២២.៦៨៣ [៤] |
| ២ - ការរំលស់បំណុលបរទេស | | 0 |
| ៣ - ហិរញ្ញប្បទានក្នុងប្រទេស | | (-) ១៩.៤៥២ |
| • ហិរញ្ញប្បទានធនាគារ | | (-) ១១៩.៥៥៧ |
| ក្នុងនោះ - ខ្ចីពីធនាគារ | | (-) ៦.១៩២ |
| - ការរំលស់បំណុលក្នុងប្រទេស | | (-) ៣.៦២២ |
| • ប្រាក់បញ្ញើផ្សេងៗទៀតនៃរតនាគារ | | (+) ៩៥.១០៥ |
| ៤ - កិច្ចប្រតិបត្តិការកំពុងដំណើរការ | | (-) ៩.៥០៥ |

(២) មិនបានគិតការរំលស់បំណុល ៩.៨១៤ លានរៀលទេ ។

(៣) បំរែបំរួលសុទ្ធនៃអាណត្តិបើកប្រាក់ដែលមានសល់មិនទាន់បានបើកផ្តល់នៅរតនាគារ និង បុរេប្រទានត្រូវធ្វើនិយ័តភាវូបនីយកម្ម ។

(៤) ក្នុងនោះមានទឹកប្រាក់ចំនួន ១.៩០៥ លានរៀល ដែលត្រូវរង់ចាំការប្រើប្រាស់ ។

# ជំពូកទី ៥
# បទប្បញ្ញត្តិស្តីពី
# ការទូទាត់ថវិការបស់ខេត្ត ក្រុង
# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

មាត្រា ៨.-

ដោយអនុលោមតាមបទប្បញ្ញត្តិ មាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស.រកម.០២៩៨.០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និងមាត្រា ១៦ នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលបានប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ ត្រូវបានយល់ព្រមតាមការអនុវត្តន៍ នូវកិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលលេចចេញជាលទ្ធផលដូចបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ ÷

ឯកតា: រៀល

| កិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ ២០០០ | ច្បាប់ទូទាត់ថវិកាខេត្ត ក្រុងឆ្នាំ ២០០០ | លើស(+) ខ្វះ(-) |
|---|---|---|---|
| សរុបចំណូល | ៤៤.000.000.000 | ៥៧.៨៨៤.៨០៨.៧៨៨ | +១៣.៨៨៤.៨០៨.៧៨៨ |
| សរុបចំណាយ | ៤៤.000.000.000 | ៥៣.៥៣២.៥៦៥.៨៤៤ | +៩.៥៣២.៥៦៥.៨៤៤ |
| អតិរេកគណនេយ្យនៃចំណូល និង ចំណាយ | | ៤.៣៥២.២៤២.៩៤៤ | +៤.៣៥២.២៤២.៩៤៤ |
| កិច្ចប្រតិបត្តិការនៃថវិការបស់ខេត្ត ក្រុង | | | |
| I. ចំណូលថវិកា | ៤៤.000.000.000 | ៥៧.៨៨៤.៨០៨.៧៨៨ | +១៣.៨៨៤.៨០៨.៧៨៨ |
| - ចំណូលជាប្រចាំ | ៤៤.000.000.000 | ៥៥.៧៤៩.០១១.៧៨៨ | +១១.៧៤៩.០១១.៧៨៨ |
| • ចំណូលសារពើពន្ធ | ១៧.៨00.000.000 | ២៨.៨៩១.៨៤០.៣០៨ | +១១.០៩១.៨៤០.៣០៨ |
| • ចំណូលពុំមែនសារពើពន្ធ | ៦.២00.000.000 | ៦.៩១៦.១៧១.៤៨០ | +៧១៦.១៧១.៤៨០ |
| • ឧបត្ថម្ភពីថវិការដ្ឋ | ២0.000.000.000 | ១៩.៩៤១.000.000 | -៥៩.000.000 |
| - ចំណូលជាមូលធន | 0 | ២.១៣៥.៧៩៧.000 | +២.១៣៥.៧៩៧.000 |
| • ចំណូលជាមូលធនផ្ទៃក្នុង | 0 | ១៣៧.000 | +១៣៧.000 |
| • ចំណូលជាមូលធននៃវិនិយោគដោយថវិការដ្ឋ (កម្មវិធីសិលា) | 0 | ២.១៣៥.៦៦០.000 | +២.១៣៥.៦៦០.000 |
| II. ចំណាយថវិកា | ៤៤.000.000.000 | ៥៣.៥៣២.៥៦៥.៨៤៤ | +៩.៥៣២.៥៦៥.៨៤៤ |
| - ចំណាយជាប្រចាំ | ៤៤.000.000.000 | ៥១.៣៩៨.៥៤៦.៧៤៤ | +៧.៣៩៨.៥៤៦.៧៤៤ |
| - ចំណាយជាមូលធន | 0 | ២.១៣៤.០១៩.១០០ | +២.១៣៤.០១៩.១០០ |
| III. អតិរេកថវិកា | 0 | ៤.៣៥២.២៤២.៩៤៤ | +៤.៣៥២.២៤២.៩៤៤ |

មាត្រា ៩.-

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ២២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស.រកម.០២៩៨.០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ អតិរេកនៃថវិការបស់ខេត្ត ក្រុង ដែលមានចំនួនទឹកប្រាក់ ៤.៣៥២.២៤២.៩៤៤ រៀល ត្រូវបានបង់ចូលថវិកាទូទៅរបស់រដ្ឋ ។

# ជំពូកទី ៦

# បទប្បញ្ញត្តិស្តីពី

# និយ័តភាពូបនីយកម្ម

# នៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែម

# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

មាត្រា ១០.-

ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ៤៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/១២៩៩/១៦ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងមាត្រា ១៦ នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ត្រូវបានយល់ព្រមផ្តល់ឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដូចខាងក្រោមនេះ ÷

- ចំណាយសំរាប់រដ្ឋសភា រៀបចំសន្និសីទសមាគមសភាអាស៊ី ដើម្បីសន្តិភាព ត្រូវបានបុរេប្រទានចំនួន ២.៩៥០ លានរៀល នៅឆ្នាំ ២០០០ ចំនួន ៨០០ លានរៀល និងនៅដើមឆ្នាំ ២០០១ ចំនួន ២.១៥០ លានរៀល ។ ចំនួនទឹកប្រាក់

ដែលនៅសល់ប្រមាណ[illegible] នឹងត្រូវធ្វើការទូទាត់ នៅក្នុងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

- ចំណាយសង្គ្រោះប្រជាជនរងគ្រោះដោយទឹកជំនន់ និង រាំងស្ងួត ព្រមទាំងចំណាយសំរាប់ស្តារហេដ្ឋារចនាសម្ព័ន្ធឡើងវិញក្រោយទឹកជំនន់ ត្រូវបានចេញអនុក្រឹត្យបន្ថែម លេខ ៩២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបន្ថែមឥណទានថវិកាចំនួន ៥៤.០០០ លានរៀល ក្នុងនោះបានធ្វើការទូទាត់ក្នុងឆ្នាំ ២០០០ ចំនួន ២៥.០០០ លានរៀល ហើយចំនួនទឹកប្រាក់ដែលនៅសល់ ២៩. ០០០ លានរៀល នឹងត្រូវធ្វើការទូទាត់នៅក្នុងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

- ប្រកាសបន្ថែមលេខ ៩៣២ ប្រក. សហវ.ថហ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការបន្ថែមឥណទានថវិកាចំនួន ៩០០ លានរៀលសំរាប់ខុទ្ទកាល័យនៃក្រសួងព្រះបរមរាជវាំង ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមករាឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជឱង្ការបង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

៣រ/ល-០៧-០១-០០៥

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ហត្ថលេខា** លេខ : ១១ ច.ល

**គាត ឈន់**

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សោម គាន**